រាជបណ្ឌិត្យសភាកម្ពុជា

# "គោលនយោបាយកសិកម្មនិងឧបត្ថម្ភធន"

( Farm Policy and Agricultural Subsidies )

បណ្ឌិត **ឆេង វណ្ណារិទ្ធ**
ប្រធានស្តីទីវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

សេចក្តីផ្តើម
ស្ថានភាពទូទៅនៃវិស័យកសិកម្មនៅកម្ពុជា
គោលនយោបាយកសិកម្ម
១. ទំហំ និងទឡ្ហីករណ៍ឧបត្ថម្ភធន( Size and Rationale )
២. សាវតា : ទស្សនាទាន ផារីធី( ទស្សនាទាន ភាពស្មើគ្នា )
( Background : The Parity Concept )
៣. ថ្លៃទ្រទ្រង់ ( Price Supports )
៤. វិធានការទប់ទល់អតិរេក( Coping with Surpluses )
សន្និដ្ឋាន
ឯកសារយោង
ឧបសម្ព័ន្ធ

## សេចក្តីផ្តើម

នៅប្រទេសកម្ពុជាវិស័យកសិកម្មបានចូលរួមចំណែកប្រមាណ២៣,៥%( គិតតាមថ្លៃបច្ចុប្បន្ន )នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០១៨ ដែលមានកម្លាំងពលកម្មក្នុងវិស័យនេះចំនួន៥៤,២%( ឆ្នាំ២០១០ ) នៃពលកម្មសរុប ហើយមកដល់ឆ្នាំ២០១៧មានចំនួន៣៧%។ ការថយចុះនៃចំនួនកសិករមួយចំនួនអាចដោយសារតែនិន្នាការចំណាកស្រុកពីជនបទទៅទីក្រុង និងចេញទៅក្រៅប្រទេសកាន់តែកើនឡើង[1]។

មូលហេតុចំណាកស្រុកពីជនបទមកទីក្រុងនិងចេញទៅក្រៅប្រទេស ដែលភាគច្រើនជាប្រជាកសិករ គឺមានគោលបំណងស្វែងរកការងារធ្វើដើម្បីទទួលបានប្រាក់ចំណូលចិញ្ចឹមជីវិតខ្លួនឯងផង និងអ្នកក្នុងបន្ទុកផង។ ម្យ៉ាងវិញទៀតដោយសារតែប្រព័ន្ធកសិកម្មនៅកម្ពុជាភាគច្រើនជាកសិកម្មផ្គត់ផ្គង់ក្នុងក្រុមគ្រួសារខ្លួនឯង ហើយតែងតែទទួលរងនូវផលប៉ះពាល់ពីបាតុភូតធម្មជាតិ ជាមួយគ្នានឹងការដាំដុះរបស់កសិករភាគច្រើនពឹងពាក់ទឹក

[1] សូមមើល : ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ទំព័រ ៤៦-៤៧

ភ្លៀង រីឯការសាងសង់ប្រព័ន្ធស្រោចស្រពពុំទាន់មានលក្ខណៈគ្រប់គ្រាន់នៅឡើយ ធ្វើឱ្យផលិតកម្មកសិកម្មមានការប្រែប្រួលជារៀងរាល់ឆ្នាំ បណ្តាលឱ្យប្រជាជនដែលរស់នៅក្នុងតំបន់ជនបទប្រកបរបរកសិកម្ម ភាគច្រើនគឺជាជនក្រីក្រ[2] បើទោះបីរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ខ្ពស់យ៉ាងណាក៏ដោយក្តី។

ស្ថានភាពដូចនេះហើយ ដែលនៅក្នុងអត្ថបទស្រាវជ្រាវនេះនឹងបង្ហាញទិដ្ឋភាពរួមនៃវិស័យកសិកម្មនៅប្រទេសកម្ពុជាបច្ចុប្បន្ន និងបង្ហាញពីវិធីដោះស្រាយវិស័យកសិកម្មរបស់សហរដ្ឋអាម៉េរិក ដើម្បីជាគំរូសម្រាប់ដោះស្រាយបញ្ហាស្រដៀងគ្នានេះនៅកម្ពុជា។

## ស្ថានភាពទូទៅនៃវិស័យកសិកម្មនៅកម្ពុជា

ក្នុងរបាយការណ៍ស្រាវជ្រាវដល់ទីកន្លែងនៅខេត្តប៉ៃលិនក្នុងឆ្នាំ២០១៥ ដោយមន្ត្រីវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃបណ្ឌិត្យសភាកម្ពុជា ហើយបានចុះផ្សាយក្នុង**ទស្សនាវដ្តីនៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំទី០១ លេខពិសេស ចេញផ្សាយថ្ងៃទី៧ ខែមករា ឆ្នាំ ២០១៩** [3] និង ក្នុង**គេហទំព័រ** ihssrac.com បានឱ្យដឹងថា ប្រជាជនសរុបក្នុងខេត្តប៉ៃលិន គឺប្រមាណ៧២%ជាកសិករដែលប្រាក់ចំណូលមធ្យមក្នុងមនុស្សម្នាក់ៗពីដំណាំស្រូវមានប្រមាណជា៥៣ដុល្លារអាមេរិកប៉ុណ្ណោះ ក្នុងមួយឆ្នាំ, ផលដំណាំស្រូវមិនសូវមានតម្រូវការពីក្រៅប្រទេសធៀបជាមួយការផ្គត់ផ្គង់ដែលធ្វើឱ្យថ្លៃធ្លាក់ចុះ ចំនួនគ្រួសារគ្មានដីស្រែចម្ការ និង មានដីស្រែ-ចម្ការតិចជាង១ហិកតា មានចំនួនជិត៤៣% (៦៦៨៩គ្រួសារ ក្នុងចំណោម ១៥ ៥៦៦គ្រួសារ)នៃប្រជាពលរដ្ឋសរុបក្នុងខេត្តប៉ៃលិន, ប្រជាពលរដ្ឋចាប់ពីអាយុ១៨-៦០ឆ្នាំមានប្រមាណជា៦០%នៃចំនួនប្រជាពលរដ្ឋសរុបក្នុងខេត្ត ប៉ុន្តែកន្លែងការងារមិនគ្រប់គ្រាន់អាចផ្តល់ការងារនិងផ្គត់ផ្គង់ជីវភាពរបស់ពួកគេបាន, វិស័យឧស្សាហកម្មភាគច្រើន គឺជាសិប្បកម្មតូចៗលក្ខណៈគ្រួសារ ប្រើប្រាស់កម្លាំងពលកម្មតិចតួចបំផុតមិនអាចស្រូបកម្លាំងពលកម្មតាមអត្រាកំណើនក្នុងខេត្ត។ ក្នុងពេលជាមួយគ្នានេះដែរ អ្នកធ្វើចំណាកស្រុកក្នុងប្រទេសនិងទៅក្រៅប្រទេសមានចំនួនកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ចំណែកឯចំនួនប្រជាជនដែលជំពាក់បំណុលឬខ្ចីប្រាក់ពីមីក្រូហិរញ្ញវត្ថុ និងធនាគារ ក៏បានកើនឡើងជាលំដាប់(ចំនួនអ្នកខ្ចីលុយពីមីក្រូហិរញ្ញវត្ថុនិងធនាគារក្នុងឆ្នាំ២០១៣មានចំនួន២៨១៨នាក់ ដល់៤៣៤៦នាក់ ក្នុងឆ្នាំ២០១៥។ ផលធៀបអ្នកខ្ចីប្រាក់ក្នុងប្រជាជន១០០០នាក់ក្នុងឆ្នាំ២០១៣មានចំនួន៤១,៤នាក់ ឡើងដល់៦៤,៩នាក់ក្នុងឆ្នាំ២០១៥)[4]។

ដោយឡែក លទ្ធផលនៃការស្រាវជ្រាវទាក់ទងនឹង **"បញ្ហា និង ដំណោះស្រាយទីផ្សារបន្លែនៅកម្ពុជា"** ដែលបានចុះផ្សាយក្នុង**ទស្សនាវដ្តីនៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជាឆ្នាំទី ០១លេខ១ ចេញផ្សាយត្រីមាសទី១(ខែមករា-មីនា)ឆ្នាំ២០១៩** និង ក្នុង**គេហទំព័រ** ihssrac.com បានសរសេរថា[5]៖ "ប្រទេសកម្ពុជានាំចូលបន្លែពីក្រៅប្រទេសមានចំនួនប្រមាណជា២០០តោនទៅ៤០០តោនក្នុងមួយថ្ងៃៗ សម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងស្រុក ហើយបន្លែទាំងនោះភាគច្រើននាំចូលពីប្រទេសវៀតណាម ថៃ និង ចិន ដោយ

---

[2] សូមមើលៈ យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និង ជនងាយរងគ្រោះ(២០១១-២០១៥),ទំព័រ២៣)

[3] សូមមើល : ទស្សនាវដ្តីនៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំទី០១ លេខពិសេស ចេញផ្សាយថ្ងៃទី៧ ខែមករា ឆ្នាំ២០១៩, ទំព័រ១-៤៣។

[4] -ដ-, ទំព័រ ១២-១៣

[5] សូមមើល : ទស្សនាវដ្តីនៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជាឆ្នាំទី០១លេខ១ចេញ ផ្សាយត្រីមាសទី១(ខែមករា-មីនា)ឆ្នាំ២០១៩, ទំព័រ ១-១១

ចំណាយថវិកាជាង២០០លានដុល្លារអាមេរិកក្នុងមួយឆ្នាំៗ។ តាមរបាយការណ៍របស់អង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិបានបង្ហាញថា«បរិមាណបន្លែដែលផ្គត់ផ្គង់នៅកម្ពុជាមានប្រមាណជិត១លានតោនក្នុង១ឆ្នាំៗ ដែលក្នុងនោះបរិមាណបន្លែផ្គត់ផ្គង់ក្នុងស្រុកមានត្រឹមតែ៤៤%ប៉ុណ្ណោះ ចំណែកការនាំចូលមានរហូតដល់៥៦%។ ដោយឡែកនៅរាជធានីភ្នំពេញបន្លែចំនួន៧០ភាគរយ គឺបន្លែនាំពីប្រទេសថៃ និងវៀតណាម ចំណែកឯបន្លែរបស់ប្រជាកសិករកម្ពុជាមានតែប្រមាណ៣០ភាគរយប៉ុណ្ណោះ"។

ការសិក្សាស្រាវជ្រាវស៊ីជម្រៅក្នុងវិស័យកសិកម្មគេបានវិភាគឃើញថា[6]៖

- ថ្លៃនិងប្រាក់ចំណូលនៅក្នុងវិស័យកសិកម្មទទួលរងនូវការឡើងចុះយ៉ាងខ្លាំងក្នុងកំឡុងរយៈពេលខ្លី ដោយសារតែតម្រូវការមិនអ៊ីឡាស្ទីក ហើយវាបានប្រែក្លាយការប្រែប្រួលតិចតួចនៃបរិមាណផលិតកម្មកសិកម្មនិងតម្រូវការទៅជាការប្រែប្រួលខ្លាំងដល់ថ្លៃនិងប្រាក់ចំណូលដែលប៉ះពាល់ខ្លាំងដល់ប្រាក់ចំណូលរបស់កសិករ។
- កំណើនតម្រូវការផលិតផលកសិកម្ម គឺតិចតួច ដោយសារតែតម្រូវការមិនអ៊ីឡាស្ទីកទៅតាមប្រាក់ចំណូល ទន្ទឹមគ្នានឹងកំណើនប្រជាជនយឺតជាទីបំផុត។
- កំណើនតិចតួចនៃតម្រូវការ បានប្រែក្លាយវិស័យកសិកម្មទៅជាវិស័យដែលថយចុះហើយធ្វើឱ្យប្រាក់ចំណូលរបស់កសិករកាន់តែតិច។

សរុបសេចក្តីមក វិស័យកសិកម្មនៅប្រទេសកម្ពុជានៅតែបន្តជួបបញ្ហាប្រឈមមួយចំនួនដូចជា ភាពងាយរងគ្រោះនៃប្រព័ន្ធដាំដុះ, ផលិតភាពនិងតម្លៃបន្ថែមនៅទាប, បច្ចេកវិទ្យាដាំដុះ, ការប្រើប្រាស់ធាតុចូលតាមបច្ចេកទេស ជាពិសេសថ្លៃនិងប្រាក់ចំណូលនៅក្នុងវិស័យកសិកម្មទទួលរងនូវការឡើងចុះយ៉ាងខ្លាំង ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ជីវភាពប្រជាកសិករខ្មែរ។

ដើម្បីចូលរួមចំណែកដោះស្រាយបញ្ហាដូចរៀបរាប់ខាងលើ ប្រធានបទនេះលើកយកបទពិសោធន៍និងដំណោះស្រាយបញ្ហាវិស័យកសិកម្មនៅសហរដ្ឋអាម៉េរិក ដើម្បីជាជំនួយស្មារតី។

## គោលនយោបាយកសិកម្ម ( FARM POLICY )

ចាប់តាំងពីឆ្នាំ១៩៣០មកវិស័យកសិកម្មរបស់អាម៉េរិកទទួលបានឧបត្ថម្ភធនយ៉ាងច្រើនសន្ធឹកសន្ធាប់។ "កម្មវិធីកសិកម្ម" រួមបញ្ចូល : ១. ថ្លៃកសិផល ប្រាក់ចំណូល និងផលិតផល, ២. ការថែរក្សាទឹក និង ដី, ៣. ការស្រាវជ្រាវវិស័យកសិកម្ម, ៤. ការផ្តល់ឥណទានដល់កសិករ, ៥. ការធានារ៉ាប់រងដំណាំ, ៦. ការឧបត្ថម្ភធនសម្រាប់ការលក់ផលិតផលកសិកម្មនៅលើទីផ្សារពិភពលោកនិងកត្តាដទៃទៀត។ កម្មវិធីនេះបានធ្វើឡើងក្នុងឆ្នាំ១៩៣០ ហើយបន្តអនុវត្តដល់បច្ចុប្បន្ន។ ក្នុងចំណោមកម្មវិធីទាំងនេះ កសិករអាម៉េរិករួមទាំងអ្នកនយោបាយបានចាត់ទុកថ្លៃនិងប្រាក់ចំណូលរបស់កសិករ គឺជា"បញ្ហាចំបងរបស់កសិករ" ដែលយើងសិក្សាជាគំរូ ។

### ១. ទំហំ និងទឡ្ហីករណ៍ឧបត្ថម្ភធន ( Size and Rationale )

ទំហំនៃឧបត្ថម្ភធនដល់កសិករអាម៉េរិក គឺមានចំនួនច្រើន។ ជាក់ស្តែងឧបត្ថម្ភធនក្នុងវិស័យកសិកម្មឆ្នាំ១៩៨៥ សម្រាប់រយៈពេលប្រាំឆ្នាំ មានចំនួន៨០ពាន់លានដុល្លារ ( $80 billion ) និង ក្នុងឆ្នាំ១៩៩០ ចំនួន៤០-៥០ពាន់លានដុល្លារ ( $40-50billion )។ ក្នុងឆ្នាំ១៩៩២ប្រាក់ចំណូលរបស់កសិករចំនួន១/៣ គឺបានមកពី

---

[6] CAMBELL R. McCONNELL & STANLEY L. BRUE "ECONOMICS: PRINCIPLERS, PROBLEMS, AND POLICIES, Thirtheenth Edition, p.665

ឧបត្ថម្ភធនរបស់រដ្ឋ ធៀបនឹងឆ្នាំ១៩៨៧ ដែលមានត្រឹមតែ២/៥ ប៉ុណ្ណោះ រហូតដល់បច្ចុប្បន្នរដ្ឋាភិបាលសហព័ន្ធចំណាយជាង២០ប៊ីលានដុល្លារក្នុង១ឆ្នាំទៅលើឧបត្ថម្ភធនសម្រាប់កសិកម្ម[7]។ កសិដ្ឋានជិត៣៩% ក្នុងចំណោមចំនួន២,១លាន នៅទូទាំងប្រទេស ដែលភាគច្រើនជាកសិដ្ឋានធំៗផលិតពោត សណ្តែកសៀង ស្រូវសាឡី កប្បាស និងស្រូវ។

រដ្ឋាភិបាលការពារកសិករពីការឡើងចុះថ្លៃ ប្រាក់ចំណូល និងទិន្នផល។ រដ្ឋាភិបាលឧបត្ថម្ភសម្រាប់ពង្រឹងការអភិរក្ស ការធានាទូទាត់សង ទីផ្សារកិច្ច ការនាំចេញ ការស្រាវជ្រាវនិងសកម្មភាពផ្សេងៗទៀត។ ហើយក៏មានទឡ្ហីករណ៍ជាច្រើនត្រូវបានលើកឡើងដើម្បីគាំទ្រការឧបត្ថម្ភធនដល់កសិករ រួមមាន៖

១. កសិករគឺប្រជាជនក្រីក្រ ដូច្នេះហើយអាចដំឡើងថ្លៃនិងទទួលប្រាក់ចំណូលបានកាន់តែច្រើនដោយសារការជួយគាំទ្ររបស់រដ្ឋ។(Farmers are comparatively poor and should therefore receive higher prices and incomes through public help)។

២. កសិករ ជាពិសេស"ក្រុមគ្រួសាររបស់កសិករ" គឺជាគ្រឹះនៃសង្គមអាម៉េរិក ដូច្នេះគប្បីត្រូវគាំទ្រជា "បែបផែននៃការរស់នៅ(Farming – and particularly the "family farm" – is a fundamental American institution and should be nurtured as a "way of life")។

៣. កសិករ គឺជាអ្នកទទួលរងគ្រោះពីធម្មជាតិជាប្រចាំដូចជា ទឹកជំនន់ គ្រោះរាំងស្ងួត សត្វចង្រៃ និងគ្រោះមហន្តរាយដទៃជាច្រើនទៀតដែលមិនអាចធានារ៉ាប់រងបាន ហើយដែលវិស័យដទៃមិនទទួលរងគ្រោះបែបនេះ(Farmers are subject to certain extraordinary hazards – floots, droughts, and invasion by hordes of in sects – to which other industries are not exposed and which cannot be fully insured)។

៤. ពេលលក់ផលិតផលរបស់ខ្លួន កសិករជួបនឹងបញ្ហាទីផ្សារប្រកួតប្រជែងខ្លាំង ប៉ុន្តែពេលទិញទំនិញ គឺពួកគេទិញពីវិស័យដែលមានអំណាចទីផ្សារ ដូចជា ក្រុមហ៊ុន ជី សម្ភារៈ បរិក្ខារ គ្រឿងយន្តកសិកម្ម ប្រេងឥន្ធនៈ។ល។ ដែលពួកគេមានលទ្ធភាពត្រួតត្រាថ្លៃទំនិញរបស់ខ្លួននៅពេលដែលកសិករទិញទំនិញពីពួកគេ។ ផ្ទុយមកវិញ ពេលដែលកសិករលក់ផលិតផលរបស់ខ្លួន គឺស្ថិតនៅក្រោមអំណាចទីផ្សារទាំងស្រុង។ វិស័យកសិកម្ម គឺជាវិស័យដែលត្រូវការពារជាចាំបាច់ពីការប្រកួតប្រជែងសុទ្ធនៅគ្រប់សេដ្ឋកិច្ចទាំងអស់ ដូច្នេះហើយវិស័យនេះ គឺត្រូវការជំនួយពីរដ្ឋដើម្បីទប់ទល់ទៅនឹងលក្ខខណ្ឌពាណិជ្ជកម្មមិនអំណោយផលដែលកើតមានឡើងទាំងអស់នេះ(រូប១)។




**រូប១. ថ្លៃផលិតផលដែលកសិករលក់និងថ្លៃទំនិញដែលកសិករទិញ ១៩១០-១៩៩០**

(Prices paid and received by farmers, 1910-1990)

ក្នុងអំឡុងពេល៥០ ចុងក្រោយនេះ ការឡើងថ្លៃទំនិញដែលកសិករទិញ គឺលឿនជាងថ្លៃផលិតផលរបស់កសិករដែលទទួលបាន។ ជាលទ្ធផលអនុបាតផារិធី (អនុបាតភាពស្មើគ្នា)(parity ratio)គឺទាបជាង ១០០%។

---

[7] https://www.downsizinggovernment.org/agriculture/subsidies

## ២. សាវតា : ទស្សនាទាន ផារីធី(ទស្សនាទាន ភាពស្មើគ្នា)

## (Background : The Parity Concept)

ច្បាប់ស្តីពីវិស័យកសិកម្មឆ្នាំ១៩៣៣(The Agricultural Adjustment Act of 1933)បានបង្កើតឡើងនូវ ***ទស្សនាទានផារីធី(ទស្សនាទានភាពស្មើគ្នា)*** ហើយដែលត្រូវបានចាត់ទុកជាបឋមសីលានៃគោលនយោបាយកសិកម្ម(The Agricultural Adjustment Act of 1933 established the ***parity concept*** as a cornerstone of agricultural policy)[8]។

ទឡ្ហីករណ៍នៃទស្សនាទានផារីធី(ទស្សនាទានភាពស្មើគ្នា)ត្រូវបានផ្អែកលើទ្រឹស្តីនិងភាពជាក់ស្តែងនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ក្នុងន័យធម្មតាផារីធី(parity)មានន័យថា នៅរៀងរាល់ឆ្នាំកសិករដោះដូរបរិមាណផលិតផលកសិកម្មដដែលដូចគ្នានេះ គឺគាត់(កសិករ)ត្រូវតែទទួលបានបរិមាណថេរមួយចំនួននៃទំនិញ និងសេវា។ បរិមាណនៃផលិតផលនេះត្រូវតែផ្គត់ផ្គង់នូវចំណូលពិតជាក់លាក់។ ឧទាហរណ៍ "ប្រសិនក្នុងឆ្នាំ១៩១២ កសិករយកស្រូវមួយតៅទៅលក់នៅទីក្រុង ហើយប្រាក់ដែលទទួលបាននេះ គាត់អាចទិញបានអាវមួយសម្រាប់ពាក់ ដូច្នេះមកដល់ពេលនេះគាត់នៅតែមានលទ្ធភាពយកស្រូវមួយតៅទៅលក់នៅទីក្រុង ហើយប្រាក់ដែលទទួលបាននេះ គាត់នៅតែអាចទិញបានអាវមួយដដែលសម្រាប់ពាក់"។

ទស្សនាទានផារីធី(ទស្សនាទានភាពស្មើគ្នា)បានកំណត់ថា ផលធៀបថ្លៃផលិតផលរបស់កសិករ និងថ្លៃទំនិញ និងសេវាដែលកសិករប្រើប្រាស់ គឺត្រូវតែនៅថេរ ។ ទស្សនាទានផារីធី(ទស្សនាទានភាពស្មើគ្នា)មានន័យថា ប្រសិនថ្លៃអាវឡើងបីដងក្នុងពេលចុងក្រោយនេះ ដូច្នេះស្រូវក៏ត្រូវបានឡើងថ្លៃបីដងដូចគ្នានេះដែរ ពោល ផារីធី១០០% ។

រូប១ បង្ហាញហេតុផលដែលកសិករទទួលបានអត្ថប្រយោជន៍ ដោយសារថ្លៃផលិតផលរបស់ពួកគេត្រូវបានផ្អែកលើផារីធី១០០% (on 100 percentof parity) និងបង្ហាញនូវឌីណាមីកថ្លៃទិញ-លក់ក្នុងអំឡុងឆ្នាំ១៩១០-១៩៩៣គិតជាភាគរយ ធៀបនឹងអំឡុងឆ្នាំមូលដ្ឋាន១៩១០-១៩៩៤។ យើងឃើញថា មកដល់ឆ្នាំ១៩៩៤ ថ្លៃទំនិញដែលកសិករបានទិញ គឺឡើងជិត១៤ដង ចំណែកឯ ថ្លៃផលិតផលរបស់កសិករបានឡើងប្រមាណជា៧ដង ធៀបអំឡុងឆ្នាំមូលដ្ឋានដូចគ្នានេះ។

**អនុបាតផារីធី**(Parity ratio)ដែលបានបង្ហាញលើរូប១ គឺជាផលធៀបថ្លៃផលិតផលរបស់កសិករលក់ទៅនឹងថ្លៃទំនិញនិងសេវាដែលកសិករទិញ។

$$\text{អនុបាតផារីធី}(\boldsymbol{Parity\ ratio}) = \frac{\text{ថ្លៃផលិតផលរបស់កសិករលក់}}{\text{ថ្លៃទំនិញនិងសេវាដែលកសិករទិញ}}$$

$$\boldsymbol{Parity\ ratio} = \frac{\boldsymbol{prices\ received\ by\ farmers}}{\boldsymbol{Prices\ paid\ by\ farmers}}$$

ឧទាហរណ៍ ក្នុងខែមេសា ឆ្នាំ១៩៩៤ អនុបាតផារីធី ស្មើនឹង៥០%(=៧/១៤)ឬ (=៧៖១៤) ពោលផលធៀបថ្លៃដែលកសិករលក់ផលិតផលរបស់ខ្លួននិងថ្លៃទំនិញដែលកសិករទិញក្នុងឆ្នាំ១៩៩៤ គឺលើសពាក់កណ្តាលធៀបក្នុងអំឡុងឆ្នាំមូលដ្ឋាន។ គោលនយោបាយកសិកម្មដែលតម្រូវឱ្យផារីធី១០០%(on 100

[8] See : https://naldc.nal.usda.gov/download/CAT87210025/PDF

percentof parity) នោះត្រូវតែកំណត់ថ្លៃកាន់តែខ្ពស់លើផលិតផលរបស់កសិករ ដើម្បីដំឡើងអនុបាតផារីធី ដល់១០០។

## ៣. ថ្លៃទ្រទ្រង់ (Price Supports)

ទស្សនាទានថ្លៃផារីធី(concept of parity prices) វាផ្តល់នូវសនិទានភាពសម្រាប់រដ្ឋាភិបាលកំណត់ថ្លៃអប្បបរមានិងថ្លៃដែលខ្ពស់លើសតុល្យការសម្រាប់ថ្លៃផលិតផលកសិកម្ម។ នៅក្នុងវិស័យកសិកម្មថ្លៃអប្បបរមាទាំងនេះ គេហៅថា ថ្លៃទ្រទ្រង់ (In agriculture these minimum prices are call price supports)។ ដោយហេតុថា ក្នុងរយៈពេលវែង ថ្លៃទីផ្សារផលិតផលរបស់កសិករ គឺឡើងយឺតជាងថ្លៃទំនិញដែលកសិករទិញមានន័យថា ដើម្បីសម្រេចបានផារីធី ឬ ខិតជិតនោះ រដ្ឋាភិបាលត្រូវកំណត់ថ្លៃគ្រប់រូបភាពសម្រាប់ផលិតផលកសិកម្ម ខ្ពស់ជាង ថ្លៃសមតាទីផ្សារ ឬ អនុវត្តថ្លៃទ្រទ្រង់។ មានកម្មវិធីជាច្រើនផ្សេងៗគ្នាដើម្បីទ្រទ្រង់ថ្លៃផលិតផលកសិកម្ម ដែលបង្ហាញនូវការព្យាយាមរបស់រដ្ឋាភិបាលប្រើប្រាស់ថ្លៃអប្បបរមា(price floors)(ថ្លៃអប្បបរមាកំណត់ដោយរដ្ឋាភិបាលនិងថ្លៃដែលខ្ពស់ជាងថ្លៃសមតាទីផ្សារ)ដើម្បីធ្វើឱ្យប្រាក់ចំណូលរបស់កសិករឡើងខ្ពស់ និងមានស្ថិរភាព(រូប២ ថ្លៃទ្រទ្រង់ $P_s$ ចំណែង ថ្លៃសមតា គឺ $P_e$។




**រូប២. ប្រសិទ្ធភាពការទ្រទ្រង់ថ្លៃ វាធ្វើឱ្យមានអតិរេកផលិតផលកសិកម្ម**

(Effective price supports result in farm surpluses)

ទស្សនាទានផារីធី តម្រូវឱ្យរដ្ឋាភិបាលទ្រទ្រង់ថ្លៃផលិតផលរបស់កសិករនៅលើកម្រិតខ្ពស់ជាងថ្លៃសមតាទីផ្សារ។ ថ្លៃដែលត្រូវបានទ្រទ្រង់នេះ វាធ្វើឱ្យមានអតិរេកជាប្រចាំនៃផលិតផលកសិកម្ម។

Application of the parity concept abligates government to support farm prices at above-equilibrium level. These supported prices result in persistent surpluses of farm products.

លទ្ធផលដែលរដ្ឋាភិបាលអនុវត្តគោលនយោបាយថ្លៃទ្រទ្រង់(Price Supports)នោះ ធ្វើឱ្យកើតចេញនូវបាតុភូតពីរយ៉ាង៖

### ទី១. ផលចំណេញសម្រាប់កសិករ(Farms Gain)

យើងឃើញថាកសិករទទួលផលចំណេញពីថ្លៃទ្រទ្រង់(រូប១) ដោយប្រាក់ចំណូលសរុបរបស់កសិករត្រូវបានឡើងខ្ពស់ពីកម្រិតប្រាក់ចំណូលដែលបានមកពីយន្តការទីផ្សារសេរី $OP_ebQ_e$ ដល់កម្រិតថ្លៃទ្រទ្រង់ $OP_saQ_s$ ។

### ទី២. អតិរេកផលិតផល(ផលិតផលលើស)(Surplus Output)

ជាមួយគ្នានេះដែរ គោលនយោបាយទ្រទ្រង់ថ្លៃ គឺបង្កើតឱ្យមានអតិរេកផលិតផលកសិកម្ម។ អ្នកប្រើប្រាស់ជាបុគ្គលចង់ទិញត្រឹម $OQ_c$ ឯកតាតែប៉ុណ្ណោះតាមថ្លៃទ្រទ្រង់ ទន្ទឹមគ្នានេះដែរកសិករចង់លក់ $OQ_s$ ឯកតា។ បរិមាណ $Q_cQ_s$ នឹងលើស(អតិរេក) តើត្រូវធ្វើបែបណាជាមួយនឹងអតិរេកទាំងនេះ?។ ចំនួនទាំងអស់នេះ

រដ្ឋាភិបាលត្រូវទិញយកតាមថ្លៃទ្រទ្រង់ពិតប្រាកដែលខ្ពស់ជាងថ្លៃសមតា។ ជាក់ស្ដែងក្នុងឆ្នាំ១៩៥០ និងឆ្នាំ១៩៦០ ទំនិញកសិផលអតិរេកជាច្រើនសន្ធឹកសន្ធាប់ត្រូវបានរដ្ឋាភិបាលទិញ និងផ្លែឈើជាច្រើនទៀតត្រូវបានរក្សាទុកបម្រុងប្រចាំថ្ងៃ ធ្វើឱ្យរដ្ឋាភិបាលមានស្រូវសាឡីនិងធុញ្ញជាតិជាច្រើនបម្រុងទុកជិតស្មើនឹងបរិមាណប្រើប្រាស់ក្នុងស្រុករយៈពេលមួយឆ្នាំ[9]។

### ៤. វិធានការទប់ទល់អតិរេក( Coping with Surpluses)

យន្តការតម្រូវការនិងការផ្គត់ផ្គង់បង្ហាញថា កម្មវិធីសំដៅកាត់បន្ថយការផ្គត់ផ្គង់ទីផ្សារ ឬ បង្កើនតម្រូវការទីផ្សារ គឺអាចជំរុញថ្លៃទីផ្សារដល់កម្រិតថ្លៃទ្រទ្រង់ដែលចង់បាន ដូច្នេះ គឺកាត់បន្ថយ ឬ លុបបំបាត់អតិរេកផលិតផលកសិកម្ម(រូប២)។

#### ក. ការដាក់កំហិតការផ្គត់ផ្គង់( Restricting Supply)

ទាក់ទងនឹងការផ្គត់ផ្គង់ គោលនយោបាយសាធារណៈរយៈពេលយូរ ត្រូវបានសំដៅទៅលើការដាក់កំហិតការផលិតកសិផល។ ជាពិសេសថ្លៃទ្រទ្រង់ត្រូវបានរួមដំណើរជាមួយនឹង***កម្មវិធីដកហូតដីធ្លីពីការធ្វើអាជីវកម្ម(ធ្វើទៅជាឥតបានការ ឬ កម្មវិធីបែងចែកដីស្រែចម្ការជាចំណែក)( "set aside" or "acreage allotment programs")***។ ដើម្បីទទួលបានថ្លៃទ្រទ្រង់សម្រាប់កសិផលរបស់ខ្លួន កសិករត្រូវតែសុខចិត្តកំហិតទំហំផ្ទៃដីដាំដុះរបស់ខ្លួន។ ដើម្បីឱ្យមានតុល្យភាពបរិមាណការផ្គត់ផ្គង់និងតម្រូវការ ក្រសួងកសិកម្មសហរដ្ឋអាម៉េរិកគណនាបរិមាណប្រហាក់ប្រហែលនៃប្រភេទកសិផលនីមួយៗដែលអ្នកប្រើប្រាស់ជាឯកជនទិញតាមថ្លៃទ្រទ្រង់ បន្ទាប់មកគណនាផ្ទៃដីដាំដុះសម្រាប់ទំនិញកសិផលទាំងអស់នោះដែលនឹងត្រូវបានទិញ។ ផ្ទៃដីដាំដុះសរុបនឹងត្រូវបាន បែងចែកតាមរដ្ឋ តាមតំបន់ និងចុងក្រោយទៅដល់កសិករជាបុគ្គលនីមួយៗ(The total acreage figure is apportioned amoung states, countries, and ultimately individual farmers.)។

មានកម្មវិធីដទៃជាច្រើនទៀត ដែលតាមរយៈកម្មវិធីទាំងនោះ ក្រសួងកសិកម្មផ្ដល់ប្រាក់ដល់កសិករផ្ទាល់សម្រាប់***ដកហូតដីធ្លីពីការធ្វើអាជីវកម្ម(ដីធ្លីមិនប្រើប្រាស់)*** ទាំងស្រុង។ ជាឧទាហរណ៍ ***"កម្មវិធីធនាគារដី"*** ("tha soil bank program")ដែលជាតុពិត គឺរដ្ឋាភិបាលបានជួលដីស្រែចម្ការពីកសិករ។ ដីស្រែចម្ការដែលមិនត្រូវបានប្រើប្រាស់ទាំងអស់នោះ ត្រូវបានដាំដំណាំជាគម្របផ្ទៃដី ឬ ដើមឈើ ប៉ុន្តែមិនដាំដើម្បីប្រមូលកសិផលសម្រាប់លក់-ដូរនោះទេ។

កម្មវិធីការដាក់កំហិតការផ្គត់ផ្គង់("supply-restricting programs) គឺកាត់បន្ថយផ្ទៃដីដាំដុះដោយមិនធ្វើឱ្យធ្លាក់ចុះបរិមាណផលិតកម្មនិងប្រែប្រួលមិនសមាមាត្រនោះឡើយ ត្បិតអីកសិករ ***ដកហូតដីធ្លីពីការធ្វើអាជីវកម្ម(ធ្វើទៅជាឥតបានការ)***នូវដីស្រែចម្ការដែលគ្មានជីជាតិ ហើយរក្សាដីស្រែចម្ការដែលល្អសម្រាប់ផលិតផលកសិកម្ម។ ដីស្រែចម្ការដែលនឹងត្រូវបានប្រើប្រាស់ ក៏នឹងត្រូវបានកែលម្អកាន់តែប្រសើរ។ ជាលទ្ធផលពូជល្អ បរិមាណ និងគុណភាពជី ថ្នាំកសិកម្មកាន់តែច្រើននឹងល្អប្រសើរឡើង ជាមួយកម្លាំងពលកម្មកាន់តែច្រើន ធ្វើឱ្យទិន្នផលកាន់តែកើនច្រើនឡើងនៅក្នុងរៀងរាល់ហិកតានៃផ្ទៃដី។ កសិករដែលមិនចូលរួមក្នុងកម្មវិធីនេះ អាចពង្រីកផ្ទៃដីដាំដុះរបស់ខ្លួនដោយរង់ចាំថ្លៃកសិផលឡើងខ្ពស់អាស្រ័យស្ថានការណ៍ទីផ្សារ។

---

[9] សូមមើល : CAMBELL R. McCONNELL & STANLEY L. BRUE "ECONOMICS: PRINCIPLERS, PROBLEMS, AND POLICIES, Thirtheenth Edition, p.668-669.

ខ. **ការគាំទ្រតម្រូវការ (Bolstering Demand)**

ដោយមានឆន្ទៈលើកកម្ពស់តម្រូវការផលិតផលកសិកម្ម រដ្ឋាភិបាលបានអនុវត្តតាមវិធីមួយចំនួន។

*១. ការប្រើប្រាស់ថ្មី (New Uses)*

រដ្ឋាភិបាលនិងវិស័យឯកជនបានចំណាយប្រាក់ជាច្រើនសម្រាប់សិក្សាស្រាវជ្រាវ ក្នុងគោលបំណងរកឱ្យឃើញនូវមធ្យោបាយប្រើប្រាស់កសិផល។ ផលិតកម្ម"**ហ្គាសូហូល**" (the production "**gasohol**") ដែលជាល្បាយប្រេងសាំងនិងអាល់កុលផលិតចេញពីធុញ្ញជាតិ គឺជាការសាកល្បងមិនអាចប្រកែកបានដើម្បីបង្កើនតម្រូវការផលិតផលកសិកម្ម។ អ្នកជំនាញភាគច្រើនបានសន្និដ្ឋានថា នេះគឺជោគជ័យដ៏ត្រចះត្រចង់មួយសម្រាប់កែច្នៃ ឬបង្កើនតម្លៃបន្ថែមសម្រាប់ផលិតផលកសិកម្ម។

*២. តម្រូវការក្នុងស្រុកនិងក្រៅស្រុក (Domestic and Foreign Demand)*

មានកម្មវិធីជាច្រើនទៀតដែលបានធ្វើឡើងសំដៅបង្កើនការប្រើប្រាស់កសិផលនៅទីផ្សារក្នុងស្រុក។ ដូចជា "**កម្មវិធីបណ្ណចំណីអាហារ**" ("**food stamp program**") ធ្វើឡើងដើម្បីគាំទ្រតម្រូវការចំណីអាហារសម្រាប់គ្រួសារមានប្រាក់ចំណូលទាប។ កម្មវិធីដូចគ្នានេះដែរ "**កម្មវិធីស្បៀងដើម្បីសន្តិភាព**" ("**Food for Peace Program**") ក្រោមច្បាប់សាធារណៈ៤៨០ ដែលអនុញ្ញាតឱ្យប្រទេសអភិវឌ្ឍន៍តិចតួចទិញកសិផលអតិរេករបស់អាម៉េរិកតាមរយៈរូបបិយបណ្ណរបស់ជាតិខ្លួន គឺមិនមែនតាមរយៈប្រាក់ដុល្លារនោះទេ (The food for Peace program under Public Law 480 has permitted less developed countries to buy American surplus farm products with their own currencies, rather than with dollars[10])។ ជារៀងរាល់ឆ្នាំប្រមាណជា២០០លានដុល្លារអាម៉េរិក ត្រូវបានចំណាយសម្រាប់ការផ្សព្វផ្សាយពាណិជ្ជកម្មនិងជំរុញកសិផលអាម៉េរិកទៅទីផ្សារពិភពលោក។ លើសពីនេះ ក្នុងពេលចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិ ប្រតិភូសហរដ្ឋអាម៉េរិកព្យាយាមបញ្ចុះបញ្ចូលដៃគូពីបរទេសឱ្យកាត់បន្ថយអត្រាពន្ធគាំពារ និងដកចេញការកំហិតដទៃទៀតសម្រាប់ទំនិញកសិផលរបស់អាម៉េរិកដែលត្រូវបាននាំចូល។

កត្តាជំរុញនិងគាំទ្រដោយរដ្ឋាភិបាលដូចនេះហើយ ដែលធ្វើឱ្យសហរដ្ឋអាម៉េរិកក្លាយជាប្រទេសនាំផលិតផលកសិកម្មចេញទៅទីផ្សារពិភពលោក ហើយប្រជាកសិករមានជីវភាពរស់នៅសមរម្យ។

## សន្និដ្ឋាន

វិស័យកសិកម្មនៅប្រទេសកម្ពុជានៅតែបន្តជួបបញ្ហាប្រឈមដូចជា ភាពងាយរងគ្រោះនៃប្រព័ន្ធដាំដុះ ផលិតភាពនិងតម្លៃបន្ថែមនៅទាប, បច្ចេកវិទ្យាដាំដុះ, ការប្រើប្រាស់ធាតុចូលតាមបច្ចេកទេស ជាពិសេសថ្លៃនិងប្រាក់ចំណូលនៅក្នុងវិស័យកសិកម្មទទួលរងនូវការឡើងចុះយ៉ាងខ្លាំង ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ជីវភាពប្រជាកសិករខ្មែរ។ ដូច្នេះការលើកកម្ពស់ផលិតភាពវិស័យកសិកម្ម ការសម្របសម្រួលរវាងតម្រូវការនិងការផ្គត់ផ្គង់ ការវិនិយោគលើវិស័យកសិកម្ម ការគិតគូថ្លៃផលិតផលកសិកម្មនិងប្រាក់ចំណូលរបស់ប្រជាកសិករ គឺជាបញ្ហាដែលត្រូវដោះស្រាយបន្ទាន់ ពីព្រោះថា វិស័យកសិកម្មនៅបន្តដើរតួនាទីសំខាន់នៅក្នុងសេដ្ឋកិច្ចជាតិ ជាពិសេសសម្រាប់កាត់បន្ថយភាពក្រីក្រ, ការកាត់បន្ថយចំណាយទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃ ការបង្កើតការងារជូនប្រជាជននិងកាត់បន្ថយចំណាកស្រុក។

---

[10] https://en.wikipedia.org/wiki/Food_for_Peace

ដើម្បីសម្រេចបាននូវដំណោះស្រាយបញ្ហាប្រឈមក្នុងវិស័យកសិកម្ម ចាំបាច់ត្រូវមានគោលនយោបាយកសិកម្មនិងឧបត្ថម្ភធនរបស់រដ្ឋាភិបាលតួយ៉ាងដូចនៅសហរដ្ឋអាម៉េរិក ដើម្បីការពារកសិករពីការឡើងចុះថ្លៃប្រាក់ចំណូល ទិន្នផល ការធានាទូទាត់សង ទីផ្សារកិច្ច ការនាំចេញ ការស្រាវជ្រាវនិងសកម្មភាពផ្សេងៗទៀត សំដៅលើកកម្ពស់ប្រាក់ចំណូលនិងជីវភាពប្រជាកសិករ៕

## ឯកសារយោង


១. *ទស្សនាវដ្តីនៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំទី០១ លេខពិសេស ចេញផ្សាយថ្ងៃទី៧ ខែមករា ឆ្នាំ២០១៩។*

២. *ទស្សនាវដ្តីនៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជាឆ្នាំទី០១ លេខ១ ចេញផ្សាយត្រីមាសទី១(ខែមករា-មីនា)ឆ្នាំ២០១៩។*

៣. *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣*

៤. *យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និង ជនងាយរងគ្រោះ(២០១១-២០១៥),ទំព័រ២៣)*

៥. *CAMBELL R. McCONNELL & STANLEY L. BRUE "ECONOMICS: PRINCIPLERS, PROBLEMS, AND POLICIES, Thirtheenth Edition.*